UNITED NATIONS
CAMBODIA

# កម្មវិធីជំនួយសង្គម និងការឆ្លើយតបចំពោះបញ្ហាកូវីដ-១៩ របស់អង្គការសហប្រជាជាតិនៅកម្ពុជា
## ឯកសារព័ត៌មានទី ៣

ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០២១

ខាងក្រោមនេះគឺជាព័ត៌មានបច្ចុប្បន្នភាព អំពីការឆ្លើយតបរបស់អង្គការសហប្រជាជាតិនៅកម្ពុជា ចំពោះការផ្ទុះជំងឺកូវីដ-១៩ និងចំពោះការអនុវត្តវិធានការឆ្លើយតបចំពោះជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្ននេះ។

- តាមរយៈការសហការយ៉ាងជិតស្និទ្ធជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិបានផ្តល់ការគាំទ្រដល់ការរៀបចំ និងការអនុវត្ត "កម្មវិធីជំនួយសង្គមក្នុងស្ថានភាពបន្ទាន់" ជាកម្មវិធីថ្មី ដែលត្រូវបានអនុវត្តក្នុងទម្រង់ជាការឧបត្ថម្ភជាសាច់ប្រាក់តែមួយលើក។ កម្មវិធីនេះនឹងត្រូវអនុវត្តនៅសប្តាហ៍ទី ១ នៃខែ មិថុនា ឆ្នាំ ២០២១។ កម្មវិធីនេះមានគោលបំណងទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលមានការលំបាកផ្នែកជីវភាពគ្រួសារដែលរងផលប៉ះពាល់ដោយសារការអនុវត្តវិធានការបិទខ្ទប់ និងគ្រួសារដែលមានសមាជិកបាត់បង់ជីវិត ឬឆ្លងជំងឺកូវីដ-១៩។ ជំនួយបច្ចេកទេសដែលផ្តល់ដល់រាជរដ្ឋាភិបាល រួមមាន៖
    - ប៉ាន់ប្រមាណពីវិសាលភាព និងទំហំសក្តានុពលនៃ "កម្មវិធីជំនួយសង្គមក្នុងស្ថានភាពបន្ទាន់" ធ្វើការកំណត់អត្តសញ្ញាណជាមុន និងចុះឈ្មោះអ្នកទទួលផលមកពីក្រុមងាយរងគ្រោះ ដូចជា ក្រុមប្រជាពលរដ្ឋដែលរស់នៅកៀកនឹងភាពក្រីក្រ ហើយដែលកំពុងប្រកបមុខរបរដែលងាយរងផលប៉ះពាល់ តាមរយៈការសហការជាមួយនឹងក្រសួងផែនការ។
    - កសាងសមត្ថភាពគ្រប់គ្រងយន្តការកំណត់អត្តសញ្ញាណ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដែលកំពុងអនុវត្តដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
    - រៀបចំក្របខ័ណ្ឌ និងឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃ (M&E) សម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដោយសហការជាមួយនឹងក្រុមប្រឹក្សាជាតិគាំពារសង្គម/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដែលប្រើប្រាស់ប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានបន្តអនុវត្ត ក្នុងរយៈពេលដែលមានការអនុវត្តវិធានការបិទខ្ទប់ និងបានផ្តល់ការឧបត្ថម្ភដល់ប្រជាពលរដ្ឋក្រីក្រជាង ៧០០ ០០០ គ្រួសារ ស្មើនឹងមនុស្សជាង ២,៨ លាននាក់។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនេះត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា ចាប់តាំងពីខែ ឧសភា ឆ្នាំ ២០២០ មក ជាមួយនឹងជំនួយបច្ចេកទេសពីអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍នានា។
- អង្គការសហប្រជាជាតិបន្តជម្រាបជូនរដ្ឋាភិបាលថា កម្មវិធីគាំពារសង្គមដែលរៀបចំបានល្អត្រូវការពារអាយុជីវិតក៏ដូចជាជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេស ក្រុមងាយរងគ្រោះជាងគេ ព្រមទាំងកសាងនូវភាពចុះ

សម្រុងគ្នានិងសាមគ្គីភាពនៅក្នុងសង្គម ក៏ដូចជាជំរុញសកម្មភាពសេដ្ឋកិច្ច។ ជាការសំខាន់ណាស់ ដែលត្រូវពង្រីកប្រព័ន្ធគាំពារសង្គមបន្ថែមទៀត ឆ្ពោះទៅសម្រេចឱ្យបាននូវការគ្របដណ្តប់ជាសកល និងធ្វើយ៉ាងណាឱ្យប្រព័ន្ធនេះកាន់តែអាចឆ្លើយតបចំពោះវិបត្តិនានា។

- លើសពីនេះ អង្គការសហប្រជាជាតិអំពាវនាវឱ្យមាន៖ ១) ការអនុវត្តវិធានការទប់ស្កាត់ការឆ្លងរាលដាលជាសកល "បែបមិនបង្កគ្រោះថ្នាក់", ២) ការពារលទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការទទួលបានស្បៀង និងបំពេញតម្រូវការចាំបាច់សំខាន់ៗ, ៣) សម្រួលឱ្យខ្សែច្រវាក់ផ្គត់ផ្គង់អាហារ និងទីផ្សារនៅតែបន្តដំណើរការ, និង ៤) បង្កើនបរិមាណ គុណភាព និងវិសាលភាពគ្របដណ្តប់នៃវិធានការសង្គ្រោះ។
- ជាមួយនឹងការផ្ទុះជំងឺកូវីដ-១៩ តាមសហគមន៍កាលពីពេលថ្មីៗនេះ គួរមានការផ្តោតការយកចិត្តទុកដាក់លើការឆ្លើយតបចំពោះស្ថានភាពអាសន្នផង ក៏ដូចជាការត្រៀមខ្លួនទប់ទល់នឹងការផ្ទុះជំងឺក្នុងទ្រង់ទ្រាយរឹតតែធំជាងនេះផង។ នេះតម្រូវឱ្យមានការរៀបចំស្តង់ដារ សម្រាប់តំបន់ដែលត្រូវបានបិទខ្ទប់ ដោយត្រូវឆ្លើយតបចំពោះបញ្ហាដំណើរការនៃទីផ្សារ ការកំណត់ប្រភេទបុគ្គលិកចាំបាច់សំខាន់ៗ ដែលមានតួនាទីបន្តរក្សាស្ថិរភាពនៃការផ្គត់ផ្គង់ស្បៀងនិងការទទួលបានស្បៀង, ការរៀបចំកញ្ចប់ស្បៀងសង្គ្រោះសម្រាប់ស្ថានភាពអាសន្ន តាមស្តង់ដារ ដែលធានាបាននូវកម្រិតអាហារូបត្ថម្ភគ្រប់គ្រាន់, កំណត់អត្តសញ្ញាណជាមុននូវក្រុមប្រជាជនដែលត្រូវទទួលបានជំនួយសង្គម ក្នុងករណីដែលវិបត្តិបន្តរីកកាន់តែធំ និងកំណត់ជាយន្តការសម្រាប់ធ្វើការសម្របសម្រួលឱ្យបានគ្រប់ជ្រុងជ្រោយជាមួយនឹងតួអង្គពាក់ព័ន្ធនានា ក៏ដូចជាការផ្សព្វផ្សាយព័ត៌មានប្រកបដោយប្រសិទ្ធភាពជាមួយនឹងសាធារណជន។
- អង្គការសហប្រជាជាតិសូមជម្រាបជូនផងដែរថា នៅកម្រិតប្រទេស រដ្ឋជាអ្នកដែលទទួលខុសត្រូវចម្បងលើការជួយ និងការពារពលរដ្ឋគ្រប់រូបដែលទទួលរងផលប៉ះពាល់ ដោយសារស្ថានភាពអាសន្នអ្វីមួយ នៅក្នុងដែនដីរបស់ខ្លួន ដូចជា តាមរយៈការផ្តួចផ្តើម រៀបចំ សម្របសម្រួល និងអនុវត្តការឆ្លើយតបមនុស្សធម៌ ជាដើម។ ប្រសិនបើមានភាពចាំបាច់ ឬការស្នើសុំ នោះអង្គការសហប្រជាជាតិអាចជួយធានាយ៉ាងណាឱ្យប្រជាពលរដ្ឋដែលជួបការខ្វះខាត អាចទទួលបានជំនួយ និងទទួលបានការការពារដែលពួកគេត្រូវការ។ ក្នុងករណីពាក់ព័ន្ធ អង្គការសហប្រជាជាតិនឹងធ្វើការតស៊ូមតិជាមួយរដ្ឋ ដើម្បីឱ្យតួអង្គក្នុងវិស័យមនុស្សធម៌ទាំងអស់អាចផ្តល់សេវាដល់ក្រុមដែលរងផលប៉ះពាល់។ ប៉ុន្តែ ការផ្តល់ជំនួយត្រូវមានការយល់ព្រមពីប្រទេសដែលរងផលប៉ះពាល់។ អង្គការសហប្រជាជាតិ និងដៃគូរបស់ខ្លួន ធ្វើការងារដើម្បីពង្រឹងសមត្ថភាពឆ្លើយតបរបស់ប្រទេស និងបំពេញបន្ថែមលើកិច្ចខិតខំប្រឹងប្រែងរបស់ជាតិ។ រាល់ជំនួយទាំងអស់ត្រូវបានផ្តល់ស្របតាមច្បាប់អន្តរជាតិ ច្បាប់ជាតិ និងគោរពតាមគោលការណ៍មនុស្សធម៌។

###

ឯកសារព័ត៌មានស្តីពីការឆ្លើយតបរបស់អង្គការសហប្រជាជាតិនៅកម្ពុជាចំពោះបញ្ហាកូវីដ-១៩ គឺជាឯកសារផ្លូវការដែលផលិតដោយអង្គការសហប្រជាជាតិនៅកម្ពុជា ដើម្បីផ្សព្វផ្សាយជូនអ្នកសារព័ត៌មាន និងដៃគូដទៃទៀត។ ឯកសារទាំងនេះត្រូវបានរៀបចំដោយការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកញ្ញា កែវ ស្រីស្រស់ មន្ត្រីទំនាក់ទំនងនិងស្វែងរកការគាំទ្រនៃការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា តាមរយៈអ៊ីមែល៖ sreysros.keo@un.org។